ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Preliminaire

**D347.1/1/7**

*តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

**សំណុំរឿងព្រហ្មទណ្ឌលេខ:** ០០៤/២/០៧-០៩-២០០៩/អវតក/កសចស(អបជ៤២)

**អង្គបុរេជំនុំជម្រះ**

**ចំពោះមុខ:**
ចៅក្រម ប្រាក់ គីមសាន ជាប្រធាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន៉ី ថុល
ចៅក្រម Kang Jin BAIK
ចៅក្រម ហួត វុទ្ធី

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 18 / 07 / 2017
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**កាលបរិច្ឆេទ:** ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ២០១៧

**សាធារណៈ: កោសលុប**

**សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងការជូនដំណឹងស្តីពីការបកស្រាយ "ការវាយប្រហារទៅលើប្រជាជនស៊ីវិល" នៅក្នុងបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាក់ទងទៅនឹងកងកម្លាំងប្រដាប់អាវុធរបស់របប ឬរដ្ឋមួយ**

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ជេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី

អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE * E.C.C.C. * C.E.T.C.

**សហមេធាវីការពារក្តីម្ចាស់បណ្តឹងឧទ្ធរណ៍**

មុំ លុជ្ស
Richard ROGERS
Göran SLUITER

ឡោ ជុនធី
សំ សុគង់
ស៊ិន សុវ៉ន
ទី ស្រ៊ីនណា
វ៉ែន ពៅ
Laure DESFORGES
Isabelle DURAND
Emmanuel JACOMY
Martine JACQUIN
Lyma NGUYEN
Nushin SARKARATI

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក”) បានទទួល “បណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងការជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ស្តីពីការបកស្រាយ “ការវាយប្រហារទៅលើប្រជាជនស៊ីវិល” នៅក្នុងបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាក់ទងទៅនឹងកងកម្លាំងប្រដាប់អាវុធរបស់របប ឬរដ្ឋនោះ” ដែលសហមេធាវីការពារក្តី [redacted] (“សហមេធាវី” និង “ម្ចាស់បណ្តឹងឧទ្ធរណ៍”) បានដាក់នៅថ្ងៃទី ១ ខែ ឧសភា ឆ្នាំ ២០១៧ (“បណ្តឹងឧទ្ធរណ៍”)[១]។

## I. សេចក្តីផ្តើម

១. បណ្តឹងឧទ្ធរណ៍នេះពាក់ព័ន្ធនឹងការជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលបានដាក់ក្នុងសំណុំរឿង ០០៤/២ នៅថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៧ ស្តីពីការបកស្រាយ “ការវាយប្រហារទៅលើប្រជាជនស៊ីវិល” នៅក្នុងបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាក់ទងទៅនឹងកងកម្លាំងប្រដាប់អាវុធរបស់របប ឬរដ្ឋនោះ (“ការជូនដំណឹងដែលរងការជំទាស់”)[២]។

## II. ប្រវត្តិនីតិវិធី

២. នៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទីបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបីទៅកាន់ការិយាល័យសហចៅក្រមស៊ើបអង្កេត ដោយចោទប្រកាន់ពីការចូលរួមរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ទៅក្នុងអំពើឧក្រិដ្ឋនានា និងបានស្នើសុំឱ្យធ្វើការចោទប្រកាន់

[១] សំណុំរឿងលេខ ០០៤/២/១៩-០៩-២០០៧-អវតក/កសចស (“សំណុំរឿង ០០៤/២”) បណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងការជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ស្តីពីការបកស្រាយ “ការវាយប្រហារទៅលើប្រជាជនស៊ីវិល” នៅក្នុងបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាក់ទងទៅនឹងកងកម្លាំងប្រដាប់អាវុធរបស់របប ឬរដ្ឋនោះ ដែលបានដាក់នៅថ្ងៃទី ១ ខែ ឧសភា ឆ្នាំ ២០១៧ និង បានជូនដំណឹងនៅថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៧ ឯកសារ D347.1/1/3 (“បណ្តឹងឧទ្ធរណ៍”)។

[២] សំណុំរឿង ០០៤/២ ការជូនដំណឹងស្តីពីការបកស្រាយ “ការវាយប្រហារទៅលើប្រជាជនស៊ីវិល” នៅក្នុងបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាក់ទងទៅនឹងកងកម្លាំងប្រដាប់អាវុធរបស់របប ឬរដ្ឋនោះ ដែលបានដាក់ជាភាសាអង់គ្លេសនៅថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៧ និង ជាភាសាខ្មែរនៅថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៧ ឯកសារ D347.1 (“ការជូនដំណឹងដែលរងការជំទាស់”)។

01504394

ទៅលើរូបគាត់[៣]។

៣. នៅថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៦ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានអញ្ជើញភាគីក្នុងសំណុំរឿង ០០៣ និង ០០៤ ព្រមទាំងអ្នកស្រាវជ្រាវ និងអង្គការដែលមានគុណវុឌ្ឍិ ឱ្យដាក់សារណា និងសារណាជាលាយលក្ខណ៍*របស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្តី* ទៅលើបញ្ហាថា តើតាមច្បាប់ទម្លាប់អន្តរជាតិនៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះ ការវាយប្រហាររបស់រដ្ឋ ឬអង្គការទៅលើកងកម្លាំងប្រដាប់អាវុធផ្ទាល់ខ្លួន អាចជាការវាយប្រហារដែលសំដៅលើប្រជាជនស៊ីវិល បើតាមគោលបំណងនៃមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែរឬទេ ("សេចក្តីអំពាវនាវសុំឱ្យដាក់សារណា")[៤]។

៤. នៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៦ សហព្រះរាជអាជ្ញាអន្តរជាតិ[៥] និងសហមេធាវីការពារក្តី [redacted][៦] [redacted][៧] និង [redacted][៨] បានដាក់សារណាជាលាយលក្ខណ៍អក្សរ។ អង្គការខាងក្រៅ និង

[៣] សំណុំរឿង ០០៤ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបីរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ឯកសារ D1។ សំណុំរឿង ០០៤ សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី អំពីការដាក់ឯកសារស្តីពី ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ ឯកសារ D1/1។

[៤] សេចក្តីអំពាវនាវសុំឱ្យដាក់សារណាពីភាគីនៅក្នុងសំណុំរឿង ០០៣ និង ០០៤ និងអ្នកដែលមិនមែនជាភាគី ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៦ ដែលបានដាក់នៅក្នុងសំណុំរឿងលេខ ០០៣/១៩-០៩-២០០៧-អវតក/កសចស ("សំណុំរឿង ០០៣") (ឯកសារ D191) និងនៅក្នុងសំណុំរឿងលេខ ០០៤/១៩-០៩-២០០៧-អវតក/កសចស ("សំណុំរឿង ០០៤") (ឯកសារ D306)។

[៥] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសេចក្តីអំពាវនាវឱ្យដាក់សារណារបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៦ ដែលបានដាក់នៅក្នុងសំណុំរឿង ០០៣ (ឯកសារ D191/1) និងនៅក្នុងសំណុំរឿង ០០៤ (ឯកសារ D306/2) ("សេចក្តីអំពាវនាវសុំឱ្យដាក់សារណា")។

[៦] សំណុំរឿង ០០៤ សារណារបស់ [redacted] ស្តីពីការបកស្រាយវាក្យស័ព្ទ "ប្រជាជនស៊ីវិល" តាមគោលបំណងនៃមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៦ ឯកសារ D306/1។

[៧] សំណុំរឿង ០០៣ សារណារបស់ [redacted] ស្តីពីសំណួរថា តើតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅឆ្នាំ ១៩៧៥-១៩៧៩ ការវាយប្រហារដោយរដ្ឋ ឬ អង្គការទៅលើកងកម្លាំងប្រដាប់អាវុធរបស់ខ្លួនអាចជាការវាយប្រការដែលសំដៅលើប្រជាជនស៊ីវិល *សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់* [redacted] *ប្រឆាំងនឹងការជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ស្តីពីការបកស្រាយ "ការវាយប្រហារទៅលើប្រជាជនស៊ីវិល" នៅក្នុងបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាក់ទងទៅនឹងកងកម្លាំងប្រដាប់អាវុធរបស់របប ឬរដ្ឋនោះ*

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

អ្នកប្រកបវិជ្ជាជីវៈផ្នែកច្បាប់ បានដាក់សារណា*អ្នកមិនមែនជាភាគីក្នុងរឿងក្តី* ចំនួន ១១[៩]។ នៅថ្ងៃទី

---

តាមគោលបំណងនៃមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ឬយ៉ាងណា ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៦ ឯកសារ D191/2។

[៨] សំណុំរឿង ០០៤ សារណារបស់ [redacted] ស្តីពីបញ្ហាថា តើការវាយប្រហារដោយរដ្ឋ ឬអង្គការមួយទៅលើសមាជិកនៃកងកម្លាំងប្រដាប់អាវុធផ្ទាល់ខ្លួន អាចត្រូវបានចាត់ទុកថាជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរ ឬយ៉ាងណា តាមច្បាប់ទម្លាប់អន្តរជាតិពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៦ ឯកសារ D306/3។

[៩] សារណាមិនមែនជាភាគីនៅក្នុងរឿងក្តី ០០៣ និង ០០៤-សាស្ត្រាចារ្យ Ben Saul ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៦ ដែលបានដាក់នៅក្នុងសំណុំរឿង ០០៣ (ឯកសារ D191/3) ដែលបានដាក់នៅក្នុងសំណុំរឿង ០០៣ (ឯកសារ D306/4)។ សារណាមិនមែនជាភាគីនៅក្នុងរឿងក្តី ០០៣ និង ០០៤ – Catherine Drummond, Philippa Webb និង Dapo Akande ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៦ ដែលបានដាក់នៅក្នុងសំណុំរឿង ០០៣ (ឯកសារ D191/4) និងនៅក្នុងសំណុំរឿង ០០៤ (ឯកសារ D306/5)។ សារណាមិនមែនជាភាគីនៅក្នុងរឿងក្តី ០០៣ និង ០០៤ – TRIAL (Track Impunity Always) ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៦ ដែលបានដាក់នៅក្នុងសំណុំរឿង ០០៣ (ឯកសារ D191/5) និងនៅក្នុងសំណុំរឿង ០០៤ (ឯកសារ D306/6)។ សារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្តី សាស្ត្រាចារ្យ Robinson, deGuzman, Jalloh និង Cryer ស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (សំណុំរឿង ០០៣ និង ០០៤) – Ido Rosenzweig ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៦ ដែលបានដាក់នៅក្នុងសំណុំរឿង ០០៣ (ឯកសារ D191/7) និងនៅក្នុងសំណុំរឿង ០០៤ (ឯកសារ D306/8)។ សារណាមិនមែនជាភាគីនៅក្នុងរឿងក្តី ០០៣ និង ០០៤ – បណ្ឌិត Joanna Nicholson ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៦ ដែលបានដាក់នៅក្នុងសំណុំរឿង ០០៣ (ឯកសារ D191/8) និងនៅក្នុងសំណុំរឿង ០០៤ (ឯកសារ D306/9)។ សារណាមិនមែនជាភាគីនៅក្នុងរឿងក្តី ០០៣ និង ០០៤ – សាស្ត្រាចារ្យ Nicholas Tsagourias ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៦ ដែលបានដាក់នៅក្នុងសំណុំរឿង ០០៣ (ឯកសារ D191/9) និងនៅក្នុងសំណុំរឿង ០០៤ (ឯកសារ D306/10)។ សារណាមិនមែនជាភាគីនៅក្នុងរឿងក្តី ០០៣ និង ០០៤ – Oliver Windridge ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៦ ដែលបានដាក់នៅក្នុងសំណុំរឿង ០០៣ (ឯកសារ D191/10) និងនៅក្នុងសំណុំរឿង ០០៤ (ឯកសារ D306/11)។ សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តីដែលចែកជូនដោយបណ្ឌិត Williams និង Grey ក្នុងការឆ្លើយតបទៅនឹងការអំពាវនាវឱ្យដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី ក្នុងសំណុំរឿង ០០៣ និង ០០៤ ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៦ ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៦ ដែលបានដាក់នៅក្នុងសំណុំរឿង ០០៣ (ឯកសារ D191/11) និងនៅក្នុងសំណុំរឿង ០០៤ (ឯកសារ D306/12)។ សារណាមិនមែនជាភាគីដាក់ដោយមជ្ឈមណ្ឌលច្បាប់អន្តរជាតិ និងច្បាប់ប្រៀបធៀប មហាវិទ្យាល័យនីតិសាស្ត្រនៃសាកលវិទ្យាល័យ Baltimore ស្តីពីនីត្យានុកូលភាពនៃការដាក់គោលដៅវាយប្រហារយោធាខ្លួនឯង ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១៦ ដែលបានដាក់នៅក្នុងសំណុំរឿង ០០៣ (ឯកសារ D191/12) និងនៅក្នុងសំណុំរឿង ០០៤ (ឯកសារ D306/13)។ ចម្លើយតបរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សនៃសាកល

***សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងការជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ស្តីពីការបកស្រាយ "ការវាយប្រហារទៅលើប្រជាជនស៊ីវិល" នៅក្នុងបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាក់ទងទៅនឹងកងកម្លាំងប្រដាប់អាវុធរបស់របប ឬរដ្ឋនោះ***

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

១១ ខែ កក្កដា ឆ្នាំ ២០១៦ សហមេធាវីការពារក្តី [redacted][១០] និង [redacted][១១] បានដាក់ចម្លើយតបរួមគ្នា។

៥. នៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៦ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរប្រឆាំងម្ចាស់បណ្តឹងឧទ្ធរណ៍[១២] បន្ទាប់មកបានចេញសេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរលើកទីពីរនៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៧[១៣]។

៦. នៅថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានដាក់ការជូនដំណឹងដែលវងការជំទាស់ទៅក្នុងសំណុំរឿង ០០៤/២។

៧. នៅថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៧ សហមេធាវីការពារក្តី [redacted] បានដាក់ការជូនដំណឹងអំពីការ

---

វិទ្យាល័យ Queen's University Belfast ទៅនឹង "ការអំពាវនាវឱ្យដាក់សារណាពីភាគីនៃសំណុំរឿង ០០៣ និង ០០៤ និងការអំពាវនាវឱ្យដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី"របស់ការិយាល័យសហចៅក្រមស៊ើបអង្កេតនៃ អ.វ.ត.ក ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១៦ ដែលបានដាក់នៅក្នុងសំណុំរឿង ០០៣ (ឯកសារ D191/13) និងនៅក្នុងសំណុំរឿង ០០៤ (ឯកសារ D306/14)។

[១០] សំណុំរឿង ០០៤ ចម្លើយតបរួមរបស់ [redacted] ទៅនឹងសារណាដែលបានដាក់ជូនដោយ*អ្នកមិនមែនជាភាគី*អនុលោមតាមឯកសារ D306 ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៦ ឯកសារ D306/16។

[១១] សំណុំរឿង ០០៣ ចម្លើយតបរួមរបស់ [redacted] តបនឹងសារណារបស់*អ្នកដែលមិនមែនជាភាគី* លើបញ្ហាដែលថា តើតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅឆ្នាំ ១៩៧៥-១៩៧៩ ការវាយប្រហារដោយរដ្ឋ ឬ អង្គការទៅលើកងកម្លាំងប្រដាប់អាវុធរបស់ខ្លួនអាចជាការវាយប្រហារដែលសំដៅលើប្រជាជនស៊ីវិលតាមគោលបំណងនៃមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ឬយ៉ាងណា ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៦ ឯកសារ D191/17។

[១២] សំណុំរឿង ០០៤/២ សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរប្រឆាំង [redacted] ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៦ ឯកសារ D334។

[១៣] សំណុំរឿង ០០៤/២ សេចក្តីជូនដំណឹងលើកទី២ អំពីការបិទកិច្ចស៊ើបសួរប្រឆាំង [redacted] ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៧ ឯកសារ D334/2។



PRE-TRIAL CHAMBER * E.C.C.C. * C.E.T.C. * CHAMBRE PRELIMINAIRE

ប្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងការជូនដំណឹងដែលរងការជំទាស់[១៤] ហើយសហមេធាវីបានដាក់សារណាលើបណ្តឹងឧទ្ធរណ៍នៅថ្ងៃទី ១ ខែ ឧសភា ឆ្នាំ ២០១៧[១៥]។

៨. តាមការណែនាំរបស់អង្គបុរេជំនុំជម្រះ[១៦] សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ចម្លើយតបរបស់ខ្លួនទៅនឹងបណ្តឹងឧទ្ធរណ៍ (“ចម្លើយតប”)[១៧] នៅថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៧។ សហមេធាវីមិនបានដាក់សារណាតបទៅតាមពេលវេលាដែលបានកំណត់ទេ។

## III. ភាពទទួលយកបាន

### ក. សារណា

៩. សហមេធាវីលើកឡើងថា បណ្តឹងឧទ្ធរណ៍អាចទទួលយកបាន អនុលោមតាមវិធាន ៧៤(៣)(ក) និង វិធាន ២១ នៃវិធានផ្ទៃក្នុង[១៨]។ ពួកគេអះអាងថា បណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបាន ដោយសារវាជាការជំទាស់ទៅលើយុត្តាធិការ អនុលោមតាមវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង ដោយសារការជូនដំណឹងដែលរងការជំទាស់ពាក់ព័ន្ធថា តើ អ.វ.ត.ក មានយុត្តាធិការក្នុងការស៊ើប

[១៤] ការជូនដំណឹងអំពីការប្តឹងឧទ្ធរណ៍លើសេចក្តីជូនដំណឹងអំពីការបកស្រាយលើ “ការវាយប្រហារលើប្រជាជនស៊ីវិល” នៅក្នុងបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលពាក់ព័ន្ធកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់រដ្ឋ ឬ របបមួយ ដែលបានដាក់នៅថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៧ និង បានជូនដំណឹងនៅថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៧ ឯកសារ D347.1/1។

[១៥] *សូមមើល ខាងលើ* ជើងទំព័រ ១។

[១៦] សំណុំរឿង ០០៤/២ ដីកាសម្រេចទៅលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំពន្យារពេលវេលាកំណត់ដើម្បីឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ស្តីពីការវាយប្រហារទៅលើប្រជាជនស៊ីវិល ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៧ ឯកសារ D347.1/1/5។

[១៧] សំណុំរឿង ០០៤/២ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិស្តីពីប្រជាជនស៊ីវិល ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៧ ឯកសារ D347.1/1/6 (“ចម្លើយតប”) ជូនដំណឹងនៅថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៧។

[១៨] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៥។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

អង្កេត និងចោទប្រកាន់បុគ្គលលើការវាយប្រហារដោយរដ្ឋ ឬដោយរបប ប្រឆាំងនឹងកងកម្លាំងប្រដាប់អាវុធខ្លួនឯង ហើយចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឬទេ ដោយ ប្រសិនបើអនុវត្ត នោះនឹងជាការបំពានទៅលើគោលការណ៍នីត្យានុកូលភាព[១៩]។ ពួកគេអះអាងបន្ថែមថា បណ្តឹងឧទ្ធរណ៍អាចទទួលយកបាន អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង ដោយសារវាបំពានទៅលើសិទ្ធិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ក្នុងការទទួលបានសច្ចភាពផ្លូវច្បាប់[២០]។

១០. នៅក្នុងចម្លើយតបរបស់ខ្លួន សហព្រះរាជអាជ្ញាអន្តរជាតិមិនជំទាស់ថា ការជូនដំណឹងដែលរងការជំទាស់គឺជា “ដីកាសម្រេច ឬសេចក្តីសម្រេច” នៅក្នុងអត្ថន័យនៃវិធាន ៧៤(៣) នៃវិធានផ្ទៃក្នុង នោះទេ ហើយថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានបំណងអនុវត្តការរកឃើញរបស់គាត់នៅក្នុងសំណុំរឿង ០០៣ និង ០០៤[២១]។ គាត់ទទួលស្គាល់បន្ថែមថា បញ្ហានៅចំពោះមុខលើកឡើងនូវសំណួរនានាដែលពាក់ព័ន្ធនឹងគោលការណ៍នីត្យានុកូលភាព និងថា តើ អ.វ.ត.ក អាចចោទប្រកាន់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិប្រឆាំងនឹងក្រុមមួយទាំងមូលនៃប្រជាជនរបស់រដ្ឋមួយ ដែលអាចស្ថិតក្នុងវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុងឬទេ[២២]។ ទោះជាយ៉ាងណាក្តី គាត់ប្រកាន់ជំហរថា បណ្តឹងឧទ្ធរណ៍ស្នើសុំឱ្យមានការបញ្ជាក់ ហេតុនេះ បណ្តឹងនេះមិនទាន់ដល់ពេលធ្វើនៅឡើយទេ ហើយបញ្ហានេះគួរត្រូវបានដោះស្រាយ តែក្នុងករណីដែលម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវបានចោទប្រកាន់បញ្ជូនទៅជំនុំជម្រះពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពាក់ព័ន្ធនឹងការវាយប្រហារទៅលើយោធាតែប៉ុណ្ណោះ[២៣]។

---

[១៩] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៦-១៨។

[២០] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២០។

[២១] ចម្លើយតប កថាខណ្ឌ ៨។

[២២] ចម្លើយតប កថាខណ្ឌ ១២។

[២៣] ចម្លើយតប កថាខណ្ឌ ១៣។

## ខ. ការពិភាក្សា

១១. អង្គបុរេជំនុំជម្រះរម្លឹកឡើងវិញថា អនុលោមតាមវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង ជនត្រូវចោទអាចប្ដឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេច ឬសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត "បញ្ជាក់យុត្តាធិការនៃ អ.វ.ត.ក"។ ការជំទាស់ទៅលើអត្ថិភាពនៅក្នុងច្បាប់នៃឧក្រិដ្ឋកម្ម និងធាតុផ្សំរបស់វានៅក្នុងអំឡុងពេលពាក់ព័ន្ធនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលប្រសិនបើយកមកអនុវត្ត នឹងនាំឱ្យមានការរំលោភលើគោលការណ៍នីត្យានុកូលភាព គឺជាការលើកឡើងពីការជំទាស់ទៅលើយុត្តាធិការលើរឿងក្ដីដែលអាចទទួលយកបាន[២៤]។ ដើម្បីសម្រេចលើភាពទទួលយកបាននៃបណ្ដឹងឧទ្ធរណ៍ អង្គបុរេជំនុំជម្រះនឹងបញ្ជាក់ថា តើការជូនដំណឹងដែលរងការជំទាស់ គឺជា "សេចក្ដីសម្រេច" ដែលអាចប្ដឹងឧទ្ធរណ៍ ទៅតាមអត្ថន័យនៃវិធាន ៧៤(៣) នៃវិធានផ្ទៃក្នុង ឬទេ ហើយប្រសិនបើអាចប្ដឹងឧទ្ធរណ៍បាន តើបណ្ដឹងនេះអាចទទួលយកបាន អនុលោមតាមវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង ជាដីកាសម្រេចដែលបញ្ជាក់អំពីយុត្តាធិការរបស់ អ.វ.ត.ក ឬទេ។ ជាជម្រើសម្យ៉ាងទៀត អង្គជំនុំជម្រះនឹងពិចារណាថា តើបណ្ដឹងនេះអាចទទួលយកបាន អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង ឬទេ។

### ១. <u>ភាពទទួលយកបាន អនុលោមតាមវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង</u>

១២. អង្គបុរេជំនុំជម្រះយល់ឃើញថា ទាំងចំណងជើង ទម្រង់ និងខ្លឹមសាររបស់ការជូនដំណឹងដែលរង

---

[២៤] សំណុំរឿង ០០៣ (អបជ ៣០) សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ [redacted] ជំទាស់ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើរបស់ [redacted] សុំការបញ្ជាក់បំភ្លឺទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងចំណងទាក់ទងជាមួយនឹងជម្លោះប្រដាប់អាវុធ ឯកសារ D87/2/1.7/1/1/7 ("សេចក្ដីសម្រេចស្ដីពីចំណងទាក់ទង") កថាខណ្ឌ ១២ *យោងទៅ* សំណុំរឿង ០០២ (អបជ ៧៥) សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ១១៧។ តុលាការ ICTY *រឿងក្ដី រដ្ឋអាជ្ញា ទល់នឹង Gotovina និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-06-90-AR72.1 សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍បន្ទាន់បន្ធូររបស់ Ante Gotovina ប្រឆាំងនឹងសេចក្ដីសម្រេចលើសំណើជាច្រើនដែលប្រឆាំងយុត្តាធិការ អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០០៧ កថាខណ្ឌ ១៥, ១៨។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

ការជំទាស់ បង្ហាញថា ការជូនដំណឹងនេះមិនមែនជា "សេចក្តីសម្រេច" ដែលអាចប្តឹងឧទ្ធរណ៍បាន អនុលោមតាមវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុងទេ វាគ្រាន់តែជាមតិយោបល់ដែលអាចស្នើសុំឱ្យមានការបញ្ជាក់ប៉ុណ្ណោះ។

១៣. ជាពិសេស អង្គបុរេជំនុំជម្រះកត់សម្គាល់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានបង្ហាញច្បាស់នៅក្នុងការជូនដំណឹងដែលរងការជំទាស់នោះថា គាត់នឹងអនុវត្តសេចក្តីសន្និដ្ឋានតាមផ្លូវច្បាប់របស់គាត់ចំពោះរឿងក្តីនេះ ទាំងក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ ឬនៅពេលសម្រេចទៅលើការចោទប្រកាន់ចំពោះជនត្រូវចោទទេ[២៥]។ ផ្ទុយទៅវិញ គាត់បានធ្វើសេចក្តីសន្និដ្ឋានថា "ជាគោលការណ៍"[២៦] ដែលសេចក្តីអំពាវនាវសុំឱ្យដាក់សារណា "ជាបញ្ហាអង្គច្បាប់ជាទូទៅ"[២៧] ក្នុងគោលបំណង "ផ្តល់ប្រយោជន៍ដល់វិស័យច្បាប់ព្រហ្មទណ្ឌអន្តរជាតិទាំងមូល"[២៨]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានទទួលស្គាល់បន្ថែមថា ភាពពាក់ព័ន្ធនៃការជូនដំណឹងដែលរងការជំទាស់ទៅនឹងការសម្រេចចោទប្រកាន់ប្រឆាំងម្ចាស់បណ្តឹងឧទ្ធរណ៍ នៅតែមានលក្ខណៈជាសម្មតិកម្មនៅឡើយ ("អាចពាក់ព័ន្ធនឹងការចោទប្រកាន់") ហើយ ត្រូវបានកម្រិត ("តិចជាង") ទាក់ទិននឹងសំណុំរឿង

---

[២៥] *សូមមើល a contrario* សំណុំរឿង ០០៣ ដីកាសម្រេចលើសំណើរបស់ [redacted] សុំការបញ្ជាក់បន្ថែមទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងចំណងទាក់ទងជាមួយនឹងជម្លោះប្រដាប់អាវុធ ចុះថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ D87/2/1.7/1 កថាខណ្ឌ ៧៨ ("[យើងនឹងមិន] តម្រូវឱ្យបង្ហាញភស្តុតាងនៃចំណងទាក់ទងនៅក្នុងការធ្វើសេចក្តីសម្រេចស្តីពីការចោទប្រកាន់ប្រឆាំងនឹង [redacted] ទេ")។ សំណុំរឿង ០០២ ដីកាសម្រេចអំពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានស្គាល់ថាជា សហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០០៩ ឯកសារ D97/13 កថាខណ្ឌ ២១ ("សហចៅក្រមស៊ើបអង្កេតយល់ឃើញថា មានមូលដ្ឋានតាមច្បាប់អន្តរជាតិសម្រាប់អនុវត្ត JCE [...]") កថាខណ្ឌ ២៣ ("ទិដ្ឋភាពទាំងនេះត្រូវបានលើកឡើងយ៉ាងត្រឹមត្រូវនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ជាពិសេសនៅក្នុងផ្នែកដែលពាក់ព័ន្ធជាមួយនឹងផែនការឧក្រិដ្ឋកម្មរួម (កថា. ៥-១៦) នៅក្នុងកថាខណ្ឌដែលពាក់ព័ន្ធនឹងការចូលរួម និងការដឹងឮរបស់ជនត្រូវចោទ និងកថាខណ្ឌ ១១៦")។

[២៦] ការជូនដំណឹងដែលរងការជំទាស់ កថាខណ្ឌ ៦៩ (សម្រេចសេចក្តី)។

[២៧] សេចក្តីអំពាវនាវសុំឱ្យដាក់សារណា កថាខណ្ឌ ៩។

[២៨] សេចក្តីអំពាវនាវសុំឱ្យដាក់សារណា កថាខណ្ឌ ៦។

០០៤[២៩]។

១៤. ហេតុនេះ ចំណងជើង ខ្លឹមសារ និងការប្រើពាក្យ ដូចជា "ជាគោលការណ៍"[៣០] ឬ "ជាទូទៅ"[៣១] ពិតជាបង្ហាញថា ការជូនដំណឹងដែលរងការជំទាស់គ្រាន់តែជាការផ្តល់មតិយោបល់ពាក់ព័ន្ធនឹងការខ្វែងយោបល់លើច្បាប់ជាធរមានប៉ុណ្ណោះ ដោយអង្គបុរេជំនុំជម្រះយល់ថាពុំសំខាន់ត្រូវដោះស្រាយនៅក្នុងដំណាក់កាលនេះ នៅក្នុងការសម្រេចទៅលើការចោទប្រកាន់នៅក្នុងសំណុំរឿង ០០៤ ទេ[៣២]។ តាមពិតទៅ ដោយសារថាវាជាបញ្ហារួម ទាំងអង្គច្បាប់ និងអង្គហេតុ[៣៣] ដោយពុំមានមូលដ្ឋានអង្គហេតុជាក់លាក់ មានតែការប៉ាន់ស្មានប៉ុណ្ណោះអាចធ្វើទៅបានចំពោះថាតើ សហចៅក្រមស៊ើបអង្កេតអាចពិចារណាយ៉ាងណាពាក់ព័ន្ធនឹងការវាយប្រហារដោយរដ្ឋ ឬអង្គការមួយទៅលើកងកម្លាំងប្រដាប់អាវុធផ្ទាល់ខ្លួន នៅក្នុងការរៀបចំសេចក្តីព្រាងដីកាដំណោះស្រាយ ដែល

[២៩] សេចក្តីអំពាវនាវសុំឱ្យដាក់សារណា កថាខណ្ឌ ៦។

[៣០] ការជូនដំណឹងដែលរងការជំទាស់ កថាខណ្ឌ ៦៩ (សម្រេចសេចក្តី)។

[៣១] សេចក្តីអំពាវនាវសុំឱ្យដាក់សារណា កថាខណ្ឌ ៨។

[៣២] *សូមមើល* ទោះបីនៅក្នុងបរិបទខុសគ្នា និងស្ថិតក្រោមបទប្បញ្ញត្តិខុសស្រឡះពីគ្នាក៏ដោយ និយមន័យនៃសញ្ញាណរបស់បញ្ហាដែលអាចប្តឹងឧទ្ធរណ៍បានដែលកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ។ តុលាការ ICC *ស្ថានភាពនៅសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ* សំណុំរឿងលេខ ICC-01/04 សាលដីកាលើពាក្យសុំរបស់រដ្ឋអាជ្ញាដែលស្នើសុំឱ្យពិនិត្យជាពិសេសទៅលើសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ I ដែលបដិសេធមិនអនុញ្ញាតឱ្យប្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៦ កថាខណ្ឌ ៩ ("អាចមានការខ្វែងយោបល់ ឬវិវាទនៃមតិយោបល់ទៅលើច្បាប់ជាធរមានចំពោះសេចក្តីសម្រេចទៅលើបញ្ហាមួយដែលលើកឡើងដើម្បីសម្រេចនៅក្នុងដំណើរការតាមផ្លូវតុលាការ។ វិវាទនៃមតិយោបល់នេះមិនបានកំណត់ពីកម្មវត្ថុដែលអាចប្តឹងឧទ្ធរណ៍បានទេ។ បញ្ហា [ដែលអាចប្តឹងឧទ្ធរណ៍បាន] ត្រូវបានកំណត់ដោយកម្មវត្ថុមួយដែលមានសារសំខាន់ក្នុងការសម្រេចសេចក្តីទៅលើបញ្ហានានាដែលបានកើតឡើងនៅក្នុងបុព្វហេតុរបស់តុលាការដែលស្ថិតក្រោមការត្រួតពិនិត្យ")។

[៣៣] អង្គបុរេជំនុំជម្រះកត់សម្គាល់ ជាឧទាហរណ៍ ថា ការជូនដំណឹងដែលរងការជំទាស់បង្ហាញថា "សំអាងហេតុ [...] ខាងលើមិនអនុវត្ត ពាក់ព័ន្ធនឹងកងកម្លាំងប្រដាប់អាវុធដែលរងការវាយប្រហារ *តាមពិត* មានសម្ព័ន្ធភាព ឬ ផ្តល់ការគាំទ្រពាក់ព័ន្ធ ទៅខាងកងទ័ពប្រឆាំងនៅក្នុងជម្លោះប្រដាប់អាវុធទេ" (គូសបញ្ជាក់បន្ថែម)។ *សូមមើល* ការជូនដំណឹងដែលរងការជំទាស់ កថាខណ្ឌ ៦៩ (សម្រេចសេចក្តី)។

អាចប្តឹងឧទ្ធរណ៍បាននោះ[៣៤]។ នៅក្នុងសេចក្តីអំពាវនាវសុំឱ្យដាក់សារណា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបញ្ជាក់បន្ថែមថា សេចក្តីសន្និដ្ឋានស្តីពីករណីជាក់លាក់នានារបស់ភាគីអាចដាក់នៅក្នុងដីកាសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាបាន នៅពេលគាត់មានមតិយោបល់លើបញ្ហាអង្គច្បាប់ និងជូនដំណឹងដល់ភាគីលើបញ្ហានេះរួចហើយ[៣៥]។

១៥. អនុលោមទៅតាមសំអាងហេតុខាងលើ អង្គបុរេជំនុំជម្រះសន្និដ្ឋានថា ការជូនដំណឹងដែលរងការជំទាស់មិនមែនជា "សេចក្តីសម្រេច" ដែលអាចប្តឹងឧទ្ធរណ៍ ទៅតាមអត្ថន័យនៃវិធាន ៧៤(៣) នៃវិធានផ្ទៃក្នុងទេ។ ជាងនេះទៀត អង្គបុរេជំនុំជម្រះយល់ឃើញថា សំណូមពរដែលសហមេធាវីបានស្នើសុំគឺជាការស្នើសុំការបញ្ជាក់ប៉ុណ្ណោះ ហើយថា ឥទ្ធិពលនៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះទៅលើបញ្ហានៅចំពោះមុខ ពាក់ព័ន្ធនឹងបទចោទ គឺគ្រាន់តែជាការប៉ាន់ស្មានប៉ុណ្ណោះ។ ហេតុនេះ ពុំចាំបាច់ពិនិត្យថា តើការបកស្រាយពាក្យថា "ការវាយប្រហារទៅលើប្រជាជនស៊ីវិល" នៅក្នុងបរិបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាក់ទិននឹងកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់រដ្ឋ ឬរបបមួយជាការជំទាស់លើយុត្តាធិការ អនុលោមតាមវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុងដែរឬទេ នោះទេ។

## ២. ភាពទទួលយកបានតាមវិធាន ២១ នៃវិធានផ្ទៃក្នុង

១៦. អង្គបុរេជំនុំជម្រះសូមរម្លឹកឡើងវិញថា វិធាន ២១ នៃវិធានផ្ទៃក្នុង មិនផ្តល់ការអនុញ្ញាតឱ្យប្តឹងឧទ្ធរណ៍ដោយស្វ័យប្រវត្តិទេ ទោះបីបណ្តឹងនោះលើកឡើងអំពីបញ្ហានៃការជំនុំជម្រះដោយយុត្តិធម៌ក៏ដោយ ហើយម្ចាស់បណ្តឹងត្រូវបង្ហាញថា កាលៈទេសៈជាក់លាក់នៃរឿងក្តី តម្រូវឱ្យមានអន្តរាគមន៍ពីអង្គជំនុំជម្រះ ដើម្បីកុំឱ្យមានព្យសនកម្ម*ដែលមិនអាចជួសជុលបាន* ចំពោះភាពយុត្តិធម៌នៃកិច្ច

---

[៣៤] *សូមមើល ឧទាហរណ៍* សំណុំរឿង ០០២ (អបជ ៦០) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចលើសំណើរបស់លោក អៀង សារី ប្រឆាំងនឹងការអនុវត្តទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ចុះថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារ D345/5/11 ("សាលដីកាស្តីពីការទទួលខុសត្រូវរបស់ថ្នាក់លើ") កថាខណ្ឌ ១១។

[៣៥] សេចក្តីអំពាវនាវសុំឱ្យដាក់សារណា កថាខណ្ឌ ៩។

ស៊ើបសួរ ឬកិច្ចដំណើរការនីតិវិធី ឬសិទ្ធិជាសារវ័ន្តរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍[៣៦]។ នៅក្នុងរឿងក្ដីនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា ពុំមានកាលៈទេសៈជាក់លាក់ដែលតម្រូវឱ្យមានអន្តរាគមន៍ពីអង្គជំនុំជម្រះទេ។ ដូចបានលើកឡើងខាងលើ ការដែលថា បណ្ដឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលនឹងត្រូវយកមកប្រើដើម្បីសម្រេចទៅលើការចោទប្រកាន់ប្រឆាំងនឹងម្ចាស់បណ្ដឹងឧទ្ធរណ៍ គ្រាន់តែជាសម្មតិកម្មសុទ្ធសាធ ហើយការលើកឡើងពីភាពចាំបាច់ក្នុងការពន្លឿនការប្ដឹងឧទ្ធរណ៍ដែលអាចមានទៅលើបញ្ហាពាក់ព័ន្ធនានានៅក្នុងដីកាដំណោះស្រាយ ក៏គ្រាន់តែជាសម្មតិកម្មសុទ្ធសាធដែរ។ អង្គបុរេជំនុំជម្រះសូមបញ្ជាក់ថា អង្គជំនុំជម្រះនឹងមិនផ្ដល់មតិយោបល់ និងមិនអាចដាក់កំហិតទៅលើការអនុវត្តឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតទាក់ទងទៅនឹងសេចក្ដីសម្រេចរបស់គាត់ដែលត្រូវបញ្ជាក់នៅក្នុងដីកាដំណោះស្រាយនោះឡើយ[៣៧]។

១៧. ហេតុនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា បណ្ដឹងឧទ្ធរណ៍នេះមិនអាចទទួលយកបានទេ។

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆ័ន្ទ៖**

- **បដិសេធ** បណ្ដឹងឧទ្ធរណ៍ដោយចាត់ទុកថាមិនអាចទទួលយកបាន។

---

[៣៦] *សូមមើល ឧទាហរណ៍* សំណុំរឿង ០០៤ (អបជ ១៦) សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងដីកាសម្រេចបដិសេធសំណើរបស់គាត់ស្នើសុំព័ត៌មានទាក់ទងនឹងករណីខ្វែងយោបល់គ្នារបស់សហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៣ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ ឯកសារ D208/1/1/2 កថាខណ្ឌ ៨។

[៣៧] *សូមមើល ឧទាហរណ៍* សាលដីកាស្ដីពីការទទួលខុសត្រូវរបស់ថ្នាក់លើ កថាខណ្ឌ ១១។

***សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងការជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ស្ដីពីការបកស្រាយ "ការវាយប្រហារទៅលើប្រជាជនស៊ីវិល" នៅក្នុងបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាក់ទងទៅនឹងកងកម្លាំងប្រដាប់អាវុធរបស់របប ឬរដ្ឋនោះ***

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចនេះបិទផ្លូវតវ៉ា។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ២០១៧

ប្រធាន ចៅក្រមអង្គបុរេជំនុំជម្រះ

ប្រាក់ គឹមសាន Olivier BEAUVALLET នេយ ថុល Kang Jin BAIK ហួត វុទ្ធី